00801592

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 04 / 2012
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៦ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤១

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

---

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Roger PHILLIPS, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោកDale LYSAK, លោក វ៉េង ហ៊ត់ |
| ជនជាប់ចោទ៖ អៀង សារី , នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT លោក Barnabé NEKUIE, លោក វ៉ែន ពៅ, លោក ឡោ ជុនធី, លោកស្រី ស៊ិន សូវ៉ន |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Philippe GOUT |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង និង ៥០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតាំងសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច | សហព្រះរាជអាជ្ញា | ៩.០៤ | ១៦.០០ |
| ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.៣០<br>១២.០០ | ១០.៣០<br>១២.០០ |
| សំណើធ្វើឡើងតាមវិធាន ៣៥ ដែលស្នើសុំឱ្យមានការស៊ើបអង្កេត និងបង្អង់នូវកិច្ចដំណើរការនីតិវិធី | មេធាវីការពារក្តី នួន ជា | ១៣.៣៥ | ១៣.៥០ |
| សំណើសុំពេលវេលាបន្ថែមសម្រាប់ការតាំងសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៤.៣៥ | ១៤.៤០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ។

**ការតាំងសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច**

សហព្រះរាជអាជ្ញាបន្តការតាំងសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច ។ មេធាវីការពារក្តី អៀង សារី ជំទាស់ទៅនឹងសំណួរដែលទាក់ទងទៅនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីសកម្ពុជា ពីព្រោះសាក្សីរូបនេះមិនមែនជាអ្នកជំនាញ ហើយលក្ខន្តិកៈរបស់បក្សយោងទៅលើរយៈពេលដែលមិនពាក់ព័ន្ធទៅនឹងសំណុំរឿងលេខ ០០២/០១ ។ មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសំណួរដែលសួរអំពីស-២១ ដោយសារអង្គហេតុនេះមិនទាក់ទងទៅនឹងសំណុំរឿង០០២/០១ ។ អង្គជំនុំជម្រះបដិសេធទៅនឹងការជំទាស់របស់មេធាវីទាំងពីរក្រុម។

**ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំ-ជម្រះសម្រេចយល់ព្រមតាមការស្នើសុំ (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។

**សំណើធ្វើឡើងតាមវិធាន ៣៥ ដែលស្នើសុំឲ្យមានការស៊ើបអង្កេត និងបង្អង់កិច្ចដំណើរការនីតិវិធី**

មេធាវីការពារក្តី នួន ជា បង្ហាញពីចេតនាក្នុងការដាក់នូវសំណើសុំឱ្យមានការស៊ើបអង្កេតទៅលើការជ្រៀតជ្រែកខាងផ្នែកនយោបាយមកលើ អ.វ.ត.ក ។ ការដាក់សំណើរនេះធ្វើឡើងដោយផ្អែកតាមសេចក្តីប្រកាសព័ត៌មាន ដែលបានធ្វើឡើងដោយចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Kasper-Ansermet ដែលមានចំណងជើងថា "កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគី ស្តីអំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឱ្យបានសមស្របក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤" ។ មេធាវីស្នើសុំឱ្យបង្អង់នូវកិច្ចដំណើរការនីតិវិធី រហូតទាល់តែការស៊ើបអង្កេតលើបញ្ហានេះ ត្រូវបានអនុវត្ត។ មេធាវីការពារក្តី ខៀវ សំផន គាំទ្រទៅនឹងការលើកឡើងនេះ ។

សហព្រះរាជអាជ្ញាលើកឡើងថាបញ្ហានេះគឺទាក់ទងទៅនឹងសំណុំរឿង ០០៣ និង ០០៤ តែប៉ុណ្ណោះ។

**សំណើសុំពេលវេលាបន្ថែមសម្រាប់ការសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច**

សហព្រះរាជអាជ្ញាស្នើសុំពេលវេលាបន្ថែមមួយថ្ងៃ (រហូតដល់ល្ងាចថ្ងៃព្រហស្បត្តិ៍) ដើម្បីបញ្ចប់ការសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ (ជារួមសហព្រះរាជអាជ្ញានឹងមានរយៈពេល ០៥ ថ្ងៃ) ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំពេលវេលាបន្ថែមចំនួន ០៣ ម៉ោង សម្រាប់ការសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំទាំងពីរ។

**Record of Rule 87(3) Proceedings**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1531 | 19.157 | 00087221-00087232, 00020162-00020189 00269951-00269970, 00290949-00290957, 00183468-00183470 00611669-00611680, 00337589-00337616 | ប្រវត្តិរូបសង្ខេបឈ្មោះ រស់ អែម, យុទ្ធជន<br><br>DC-Cam Statement of RUOH Aem Brief biography of Ruos Emf, militant. | P | | | |
| E3/1052 | D108/7.7 | 00173458-00173465 00289848-00289862 00221962-00221965 | ឧបសម្ព័ន្ធ ៧៖ 85bbkkh សម្រង់ចម្លើយសារភាពរបស់ ចាន់ មុល ហៅ តុល<br>Annex 7: 85bbkkh Colour copy Excerpt of Confession of Chan Mon alias Tol<br><br>Annexe 7: 85bbkkh l'extrait en copie couleur de la confession de Chan Mol alias Tol | P | | | |

| **<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>** |
|---|
| • អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣១) និង នួន ជា (ម៉ោង ១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ ។<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សី កាំង ហ្គេចអ៊ាវ ត្រឡប់ទៅមន្ទីរឃុំឃាំង និងបង្គាប់ឱ្យនាំខ្លួនគាត់មកកាន់សាលសវនាការវិញនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ មុនម៉ោង ៩.០០ នាទីព្រឹក។<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២។ |

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ២៧ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.R.C.

ឌុច ផារី Roger PHILLIPS